ក្រសួងឧស្សាហកម្ម និងសិប្បកម្ម រៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៩ ទិវាអន្តរជាតិ៨មីនា ឆ្នាំ២០២០ នៅទីរួមខេត្តសៀមរាប



ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៩ ទិវាអន្តរជាតិ៨មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ "មានសន្តិភាព មានការលើកកំពស់សមភាពយេនឌ័រ " ត្រូវបានប្រារព្ធធ្វើឡើងនៅព្រឹកថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ នៅសណ្ឋាគារ Angkor Miracle Resort &Spaខេត្តសៀមរាប ។

បន្ទាប់ពីលោកស្រី ឡៃ វលក្ខ័ណា តំណាងមកពីរដ្ឋាករទឹកក្រុងភ្នំពេញ អានប្រវត្តិនារី ០៨ មីនា លោកជំទាវ ឡាយ ណាវីន រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម អានព្រះរាជសារ សម្តេចព្រះមហាក្សត្រីយ៍នរោត្តមមុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងរបាយការណ៍សកម្មភាព សមាគមនារី អានដោយលោកស្រី ទេព វ៉ានី ប្រធាននារីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួចមក លោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការតំណាងក្រសួងកិច្ចការនារី បានមានប្រសាសន៍វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមការដឹកនាំរបស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ធ្វើឲ្យបងប្អូននារីជាមន្ត្រីរាជការទទួលបានឋានៈតួនាទី សមតាមសមត្ថភាព និងការបណ្តុះបណ្តាល បង្កើនកំរិតចំណេះដឹងបានយ៉ាងប្រសើរ ។ ជាក់ស្តែងតាមរបាយការណ៍ ដែលអានដោយលោកស្រីប្រធាននារីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រហូតដល់បច្ចុប្បន្ននេះ មន្ត្រីរាជការ និងមន្ត្រីជានយោជិកជានារី មានការកើនឡើងគួរជាទីមោទនក្រៃលែង ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងក្នុងតួនាទីសម្រេចចិត្ត និងក្នុងគ្រប់កំរិតបន្តបន្ទាប់ ។



ជាមួយគ្នានេះ លោកជំទាវរដ្ឋលេខាធិការក៏បានលើកឡើងពីប្រវត្តិសាស្រ្តកម្ពុជា ដែលប្រកាន់យកមាគ៌ាមាតាធិបតេយ្យ ហើយបច្ចុប្បន្នក្រោមការដឹកនាំដ៏វៀងវៃប្រកបដោយកិត្តិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្រ្តី នារីបានឈរក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត និងក្នុងគ្រប់កំរិតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានចំនួនដ៏ច្រើន លើសសង្គមណាៗទាំងអស់ ។ និយាយដោយខ្លីគឺមានចំនួន៥១% នៃចំនួនមន្រ្តីរាជការទាំងអស់ ។ ជាមួយគ្នានេះ លោកជំទាវ រដ្ឋលេខាធិការ បានរំលេចឡើងនូវសារៈសំខាន់ នៃការជ្រើសរើសប្រធានបទខាងលើ គឺដើម្បីរំលឹកអំពីគុណតម្លៃ ដែលមិនអាចកាត់ថ្លៃបាន នៃសុខសន្តិភាព អរគុណដល់សន្តិភាព ដែលមានស្ថាបនិកដ៏ឆ្នើមរបស់ប្រទេសកម្ពុជា គឺសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំប្រទេសទទួលបាននូវសុខសន្តិភាព និងការអភិវឌ្ឍនិរីកចម្រើនរហូតដល់បច្ចុប្បន្ននេះ ។



មានប្រសាសន៍សំណេះសំណាលនាឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្រ្តី ចម ប្រសិទ្ធ បានបង្ហាញនូវទឹកចិត្តរីករាយវាយតម្លៃខ្ពស់ចំពោះការរៀបចំពិធីនាថ្ងៃនេះ នៅទីរួមខេត្តសៀមរាប ដែលជាចំណែកមួយនៃការលើកកំពស់វិស័យទេសចរណ៍របស់ជាតិយើង ។ ជារៀងរាល់ឆ្នាំ

ប្រទេសកម្ពុជា បានរៀបចំយុទ្ធនាការទិវាអន្តរជាតិនារី ៨ មីនា ដើម្បីរំលឹកពីការតស៊ូទាមទារសិទ្ធិសេរីភាព និងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព សមិទ្ធិផល បញ្ហាប្រឈម ការប្តេជ្ញាចិត្ត និងវិធានការជាវិជ្ជមាននានាក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងក្មេងស្រី ទិវានេះពិតជាមានសារៈសំខាន់ណាស់សម្រាប់បងប្អូននារីគ្រប់ៗរូប មិនថានៅប្រទេសកម្ពុជា ឬនៅក្នុងពិភពលោកនោះទេ។ ទិវានេះត្រូវបានចាប់បដិសន្ធិឡើងចាប់តាំងពីឆ្នាំ១៩១១ បើគិតមកទល់ពេលនេះមាន រយៈពេល១០៩ឆ្នាំ។ ចំពោះប្រទេសកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ស្ថានភាពជីវភាព សិទ្ធិ ឋានៈ តួនាទី និងសុខុមាលភាពរបស់ស្ត្រី តាមរយៈការបង្កើតជាសេនាធិការប្រតិបត្តិជាច្រើន ដែលរួមមានក្រសួងកិច្ចកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមាន សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាព្រះប្រធានកិត្តិយស គណៈកម្មាធិការជាតិលើកកម្ពស់សីលធិមសង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ថ្នាក់កណ្តាល ដែលមានសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ជាប្រធានកិត្តិយស និងលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រុមការងារយេនឌ័រ និងគណៈកម្មការប្រតិបត្តិសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅតាមក្រសួង - ស្ថាប័នទាំងអស់ ។
តាមទិដ្ឋភាពនេះយើង មើលឃើញថា រាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់ខ្ពស់បំផុតលើការងារបញ្ជ្រាបយេនឌ័រ ដើម្បីបង្កើនភាពអង់អាច ការសម្រេចចិត្ត និងសេចក្តីថ្លៃថ្នូរបស់ ស្ត្រីនារី និងកុមារី ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ក៏បានបញ្ជាក់រំលឹកផងដែរថា៖ទន្ទឹមនិងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលនិងក្រសួងលេីការងារបញ្ជ្រាបយេនឌ័រ ក្នុងគ្រប់វិស័យ ស្ត្រីខ្លួនយេីង ដែលកំពុងមានតួនាទីដ៏សំខាន់ក្នុងខឿនសេដ្ឋកិច្ច និងគ្រួសារ ត្រូវខិតខំបង្កេីនចំណេះជំនាញពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងជាពិសេសធ្វេីជាបង្គោលគ្រួសារដ៏រឹងមាំ ដេីម្បីគ្រួសាររុងរឿង និងសង្គមជាតិរុងរឿងរួមគ្នា ។
ស្ថិតក្នុងឱកាសនោះ អង្គពិធីក៏បានរៀបចំពិធី ប្រគល់បាច់ផ្កា និងវត្ថុអនុស្សាវរីយ៍ជូនគ្នាទៅវិញទៅមក ក្នុងចំណោមគណៈអធិបតី ថ្នាក់ដឹកនាំជាស្ត្រី និងរវាងគ្រួសារ ។ ដោយឡែកឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត និងលោកជំទាវ ក៏បានឧបត្ថម្ភថវិកាប្រចាំឆ្នាំសម្រាប់ការងារនារីក្រសួងចំនួន

១០០០ដុល្លារអាមេរិក លើសបណ្តាឆ្នាំមុនៗ ក្នុងចំនួនតែ៥០០ ដុល្លារអាមេរិក ព្រមទាំងឧបត្ថម្ភថវិការមួយចំនួនដល់មន្ត្រីរាជការនយោជិកជានារីទាំងអស់ របស់ក្រសួងផងដែរ ។

